00549255

E186

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 09 / 07 / 2010
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

គោរពជូន: លោកចៅក្រម និល ណុន
ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន: ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
លោកមេធាវីការ សាវុត្ថ
លោកមេធាវី Francois Roux

ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១០

**កម្មវត្ថុ: សំណើរបស់លោក កាំង ហ្កេកអ៊ាវ សុំដកសហមេធាវី Francois Roux**

លោកប្រធាន និល ណុន ជាទីគោរព,

1. នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១០ ខ្ញុំបានទទួលលិខិតមួយច្បាប់ពីលោក កាំង ហ្កេកអ៊ាវ ស្នើសុំដកសហមេធាវីបរទេសរបស់គាត់ គឺលោក Roux (ចាប់ពីទីនេះតទៅហៅថា “សំណើ”)។ នៅក្នុងសំណើរបស់គាត់ លោក កាំង បានថ្លែងថាគាត់បានបាត់បង់ទំនុកចិត្តលើលោក Roux និង បានផ្តល់មូលហេតុបីដូចខាងក្រោម ។

**នីតិវិធី និង មូលហេតុ**

2. នីតិវិធីពិតប្រាកដសម្រាប់ផ្លាស់ប្តូរសហមេធាវីមិនបានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវីរបស់ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាវិធានផ្ទៃក្នុង ឬ បទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី (DSS) ដែរ ។ តាមការយល់ឃើញរបស់ខ្ញុំ នីតិវិធីត្រឹមត្រូវ គឺឲ្យអង្គភាពគាំពារការការពារក្តីធ្វើសេចក្តីសម្រេចរដ្ឋបាលលើសំណើនេះ ហើយបញ្ជូនសំណើនេះទៅអង្គជំនុំជម្រះពាក់ព័ន្ធ ដែលនៅក្នុងករណីនេះ គឺអង្គជំនុំជម្រះសាលាដំបូង ដើម្បីយល់ព្រម (បដិសេធ ឬសម្រេចផ្សេងពីនេះ) ។ វិធីសាស្ត្របែបនេះនឹងឆ្លុះបញ្ចាំងពីនីតិវិធីចាត់តាំងមេធាវីការពារក្តី ដែលអង្គភាពគាំពារការការពារក្តីនឹងចាត់តាំង ហើយសហចៅក្រមស៊ើបអង្កេតនឹងយល់ព្រមលើការចាត់តាំងនេះ ។ អង្គភាពគាំពារការការពារក្តីនឹងដំណើរការដោយលើមូលដ្ឋាននេះ ។



ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 09-Jul-2010, 15:02
Sann Rada

00549256

E186

3. មូលហេតុសម្រាប់បការណ្តេញសហមេធាវីមានចែងនៅក្នុងបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី ។ មាត្រា ៧.២ ចែងថា:

    *ការផ្លាស់ប្តូរមេធាវី:* ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទអាចដាក់ពាក្យទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សុំផ្លាស់ប្តូរសហមេធាវីទាំងពីរ ឬសហមេធាវីណាម្នាក់ក្នុងចំណោមពួកគេ ។ ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ អាចត្រូវបានអនុញ្ញាតឲ្យផ្លាស់ប្តូរសហមេធាវី តែនៅក្នុងករណីពិសេសប៉ុណ្ណោះ" ។

4. ការពិនិត្យលើវិធីសាស្ត្រដែលបានអនុវត្តនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ឬ តុលាការឧក្រិដ្ឋកម្មកូនកាត់ដទៃទៀត បង្ហាញថាសំណើរបស់ជនជាប់ចោទសុំដកមេធាវីការពារក្តីរបស់ពួកគេជាទូទៅត្រូវបានទទួលយក ប្រសិនបើមានការបាត់បង់ទំនុកចិត្តពិតប្រាកដមែន និងមិនបង្កឲ្យមានការពន្យាដំណើរការនីតិវិធីដោយមិនត្រឹមត្រូវ ។ តុលាការបានច្រានចោលសំណើជាច្រើននៅពេលដែលសំណើសុំដកមេធាវីការពារក្តីមានចេតនារារាំងដល់ដំណើរការនីតិវិធី ។ យើងខ្ញុំបានរកឃើញករណីតែមួយគត់ដែលសំណើរបស់ជនជាប់ចោទ សុំដកមេធាវីការពារក្តីរបស់គាត់ គឺកើតឡើងបន្ទាប់ពីសវនាការបានបញ្ចប់ ប៉ុន្តែនៅមុនការចេញសាលក្រម ។ នៅក្នុងករណីនេះតុលាការបានយល់ព្រមលើសំណើ ដោយឈរលើមូលដ្ឋានថា: "សវនាការរបស់ជនជាប់ចោទបានបញ្ចប់ ហើយកំពុងរងចាំការចេញសាលក្រម ហើយដូច្នេះ ការដកមេធាវីការពារក្តីនឹងមិនបង្កឲ្យមានការពន្យាដំណើរនីតិវិធីបច្ចុប្បន្ននោះទេ" ។ (សូមមើលដីកាសម្រេចលើរឿងក្តី *Tadic* (IT-94-1) ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៧) ។

**សេចក្តីសម្រេចផ្នែករដ្ឋបាល**

5. អង្គភាពគាំពារការការពារក្តីយល់ព្រមលើសំណើរបស់លោក កាំង ហ្គេកអ៊ាវ សុំដកមេធាវីបរទេសរបស់គាត់ គឺលោក Roux ។

6. នៅក្នុងការធ្វើសេចក្តីសម្រេចនេះ អង្គភាពគាំពារការការពារក្តីបានកត់សំគាល់ដូចខាងក្រោម:
    ក. ពុំមានមូលហេតុអ្វីដែលត្រូវសង្ស័យថាការបាត់បង់ទំនុកចិត្តរបស់លោក កាំង ហ្គេកអ៊ាវ គឺមិនពិតនោះទេ ។
    ខ. ពុំមានមូលហេតុអ្វីដែលត្រូវសង្ស័យថា សំណើសុំដកមេធាវីការពារក្តីមានចេតនារារាំងដល់ដំណើរការនីតិវិធីដែរ ។
    គ. ការដកលោក Roux នៅដំណាក់កាលនេះនឹងមិនបង្កឲ្យមានការពន្យាដំណើរការនីតិវិធីដោយមិនត្រឹមត្រូវដែរ ។

E186

ឃ. ការបាត់បង់ទំនុកចិត្តបង្កើតឱ្យមានករណីពិសេស ។

7. សេចក្តីសម្រេចនេះមិនមែនជាការគាំទ្រដល់មូលហេតុនៃការបាត់បង់ទំនុកចិត្ត ដែលត្រូវបានលើកឡើងនៅក្នុងសំណើរបស់លោក កាំង ហ្គេកអ៊ាវ នោះទេ ។ នៅក្នុងកាលៈទេសៈនេះ វាមិនចាំបាច់ទទួលយក ឬ បដិសេធមូលហេតុទាំងអស់ខាងលើនេះ ។

8. អង្គភាពគាំពារការការពារក្តីសូមឱ្យអង្គជំនុំជម្រះសាលាដំបូងយល់ព្រមលើការដកលោក Roux ជាសហមេធាវីបរទេសរបស់លោក កាំង ហ្គេកអ៊ាវ ។

ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ,

Richard J Rogers
**ប្រធានអង្គភាពគាំពារការពារក្តី**